មជ្ឈមណ្ឌលឯកសារកម្ពុជា

**BBI0069**

# សម្ភាសន៍ជាមួយឈ្មោះ ទេព ឆូវ ភេទប្រុស អាយុ៦៤

មានស្រុកកំណើតនៅភូមិព្រៃចេក ឃុំត្រពាំងរាំង ស្រុកឈូក ខេត្តកំពត

សព្វថ្ងៃរស់នៅភូមិស្វាយជ្រុំ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង

សម្ភាសន៍ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១១

មុខងារសម័យខ្មែរក្រហមៈ ឈ្លបភូមិ

មុខងារបច្ចុប្បន្នៈ កសិករ

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

សរុបទំព័រៈ ២៦

វណ្ណៈ៖ អញ្ជើញជាដំបូងខ្ញុំសូមណែនាំខ្លួនខ្ញុំថាខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ឆូវៈ បាទ!

វណ្ណៈ៖ ខ្ញុំឈ្មោះសុខ វណ្ណៈ ហើយខ្ញុំមកដល់ភូមិស្រុកកំរៀងនេះខ្ញុំចង់ដឹងពីប្រវត្តិរឿងរ៉ាវបងប្អូនដែលខំតស៊ូរត់ក្នុងព្រៃយ៉ាងម៉េច ហើយពីតូចមករៀនបានត្រឹមណា ឈប់រៀនដោយសារមូលហេតុអី បងប្អូនដូចថាចេញពីឪពុកម្តាយអញ្ជើញណាពូ សូមពូជួយឆ្លើយឲ្យពូបន្តិចដើម្បីឲ្យវាស្រួប?

ឆូវៈ បាទ!

វណ្ណៈ៖ អញ្ជើញជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

ឆូវៈ ខ្ញុំឈ្មោះទេព ឆូវ ។

វណ្ណៈ៖ ពូអាយុប៉ុន្មានហើយ?

ឆូវៈ អាយុ៦៤ឆ្នាំ ។

វណ្ណៈ៖ ចុះប្រពន្ធពូឈ្មោះអីដែរ?

ឆូវៈ ឈ្មោះប្រាក់ រុន ។

វណ្ណៈ៖ គាត់អាយុប៉ុន្មានហើយ?

ឆូវៈ អាយុ៥៦ឆ្នាំ ។

វណ្ណៈ៖ ពូសព្វថ្ងៃមានកូនប៉ុន្មាននាក់?

ឆូវៈ មានកូន៦នាក់ ។

វណ្ណៈ៖ ស្រីប៉ុន្មាន ហើយប្រុសប៉ុន្មាន?

ផ្លូវៈ តាមពិតនៅតែ៥ទេព្រោះស្លាប់មួយហើយ ។

វណ្ណៈ អញ្ចឹងទាំងអស់៦នាក់ ហើយស្លាប់មួយសល់៥នាក់?

ផ្លូវៈ ប្រុស៣នាក់ ហើយស្រី២នាក់ ។

វណ្ណៈ ឪពុករបស់ពូឈ្មោះអីដែរ?

ផ្លូវៈ ឈ្មោះទេព គិន ។

វណ្ណៈ ចុះម្ដាយ?

ផ្លូវៈ ប្រាក់ សែម ។

វណ្ណៈ ចុះបងប្អូនបង្កើតរបស់ពូមានប៉ុន្មាននាក់?

ផ្លូវៈ មានតែ៤នាក់ទេ តែស្លាប់អស់២នាក់នៅសល់តែ២នាក់ទេ ។

វណ្ណៈ បងប្អូនបង្កើត៤នាក់ ហើយប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ផ្លូវៈ ប្រុស២នាក់ ស្រី២នាក់ ។

វណ្ណៈ ហើយសព្វថ្ងៃសល់២នាក់?

ផ្លូវៈ សល់២នាក់ ។

វណ្ណៈ ចុះ២នាក់ទៀតបាត់ខ្លួនឈ្មោះអីទៅ ដឹងថាស្លាប់?

ផ្លូវៈ ស្លាប់បងខ្ញុំនោះឈ្មោះម៉ៅ ។

វណ្ណៈ ឈ្មោះទេព ម៉ៅ?

ផ្លូវៈ បាទ! ស្រី ។

វណ្ណៈ គាត់ស្លាប់ដោយសារអី?

ផ្លូវៈ ដោយសារសង្គ្រាម ។

វណ្ណៈ សង្គ្រាមឆ្នាំណា?

ផ្លូវៈ ស្លាប់កាលដឹកគ្រាប់ដឹកអីហ្នឹង ។

វណ្ណៈ ៧៩?

ផ្លូវៈ មិនមែន៧៩ទេ ។

វណ្ណៈ ប៉ុន្មាន ហើយដឹកឆ្នាំណា?

ផ្លូវៈ ខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ ជំនាន់ប៉ុល ពតឬក៏ជំនាន់ណា?

ផ្លូវៈ ជំនាន់ប៉ុល ពត ។

វណ្ណៈ  ចុះម្នាក់ទៀត?

ឆ្នូវៈ  ម្នាក់ទៀតស្លាប់កាលវៃគ្នាជាមួយយួនហ្នឹង ។

វណ្ណៈ  ឈ្មោះអី?

ឆ្នូវៈ  ឈ្មោះទេព  ឈន ។

វណ្ណៈ  ពេលវៃជាមួយយួនមែន?

ឆ្នូវៈ  បាទ!

វណ្ណៈ  ចុះឪពុកម្ដាយពូស្លាប់អស់ហើយឬក៏នូវ?

ឆ្នូវៈ  ស្លាប់អស់ហើយ ។

វណ្ណៈ  គាត់ស្លាប់ក្រោយ៧៩ឬក៏ឆ្នាំណា?

ឆ្នូវៈ  គាត់ទើបតែស្លាប់៣,៤ឆ្នាំនេះ ។

វណ្ណៈ  អញ្ចឹងគាត់ស្លាប់ក្រោយ៧៩?

ឆ្នូវៈ  បាទ!

វណ្ណៈ  គាត់ចាស់អស់ហើយ?

ឆ្នូវៈ  ចាស់ហើយ ។

វណ្ណៈ  ចុះភូមិកំណើតពូនៅភូមិអី?

ឆ្នូវៈ  នៅភូមិព្រៃចេក ។

វណ្ណៈ  ឃុំ?

ឆ្នូវៈ  កាលហ្នឹងគេហៅឃុំត្រពាំងរាំង  ឥលូវនេះគេហៅឃុំដេរូង ។

វណ្ណៈ  ហើយស្រុក?

ឆ្នូវៈ  ស្រុកឈូក  ខេត្តកំពត ។

វណ្ណៈ  ចុះសព្វថ្ងៃពូនៅភូមិអី?

ឆ្នូវៈ  នៅភូមិស្វាយជ្រំ ។

វណ្ណៈ  ឃុំ?

ឆ្នូវៈ  ឃុំអូរដា  ស្រុកកំរៀង ។

វណ្ណៈ  ខេត្ត?

ឆ្នូវៈ  បាត់ដំបង ។

វណ្ណៈ  កាលពីតូចពូរៀនដល់ថ្នាក់ណា?

ឆ្លូវៈ រៀនដល់ថ្នាក់ទី៩ ។

វណ្ណៈ ទី៩ចាស់?

ឆ្លូវៈ បាទ!

វណ្ណៈ រៀនបានតិច?

ឆ្លូវៈ រៀនបានតិច ។

វណ្ណៈ ពេលឈប់រៀនពូចេញទៅណា?

ឆ្លូវៈ ពេលឈប់រៀននៅផ្ទះ ។

វណ្ណៈ នៅផ្ទះជួយធ្វើការឪពុកម្តាយ?

ឆ្លូវៈ បាទ!

វណ្ណៈ ឈប់រៀនដោយសារមូលហេតុអី?

ឆ្លូវៈ ឈប់រៀនដោយសារសង្គ្រាម ។

វណ្ណៈ ចុះពូថាពូចូលចលនាតាំងពីឆ្នាំ១៩៦៨?

ឆ្លូវៈ ៦៨,៦៩,៧០ ។

វណ្ណៈ ៧០ហ្នឹងរដ្ឋប្រហារទម្លាក់សម្តេចនោះ?

ឆ្លូវៈ ប៉ុន្តែក្នុងហ្នឹងគេទម្លាក់អាវុធហើយពេលហ្នឹង កាល៦៨ ។

វណ្ណៈ អញ្ចឹងពូចូលតាំងពីពេលហ្នឹង?

ឆ្លូវៈ បាទ!

វណ្ណៈ ចលនាក្នុងភូមិមែន?

ឆ្លូវៈ បាទ!

វណ្ណៈ អញ្ចឹងដល់ពេល៦៩,៧០,៧១ពូធ្វើអីនៅក្នុងភូមិ?

ឆ្លូវៈ អាហ្នឹងចូលព្រៃហើយ គេចូលព្រៃហើយអ្នកមានខ្លួនមានស្បែកមុខណា៎ ។

វណ្ណៈ ឆ្នាំណាដែលចូលព្រៃ?

ឆ្លូវៈ ឆ្នាំ៦៨ហ្នឹង ។

វណ្ណៈ ចលនាក្នុងភូមិហ្នឹងចូលព្រៃ?

ឆ្លូវៈ បាទ!

វណ្ណៈ ពូចូលព្រៃកាលជំនាន់ពូចូលហ្នឹង?

ឆ្លូវៈ ខ្ញុំមិនចូលទេ ខ្ញុំបែកមុខ ។

វណ្ណៈ៖ បែកមុខម៉េចទៅ?

ឆ្នូវៈ គេដាក់ឈ្មោះថាយើងហ្នឹងជាប់ខ្សែស្រឡាយខាងប៉ុល ពត ។

វណ្ណៈ៖ អាហ្នឹងគេហៅថាបែកមុខ?

ឆ្នូវៈ បែកមុខដូចថាឪពុកម្ដាយរត់ចូលព្រៃអញ្ចឹងហើយ នៅកូននៅអីអញ្ចឹងរៀនហើយចូលព្រៃទៀត ។

វណ្ណៈ៖ អញ្ចឹងពូចូលព្រៃទាំងគ្រួសារហ្នឹង?

ឆ្នូវៈ ខ្ញុំអត់ចូលទេ ចូលតែអ្នកបែកមុខ ហើយបែកមុខហ្នឹងចង់និយាយថាគេឪពុកម្ដាយគេចូលព្រៃអញ្ចឹងទៅ.. ។

វណ្ណៈ៖ កូនចៅចូលដែរ?

ឆ្នូវៈ កូនចៅហ្នឹងបើថាគេរករឿងគេកោះហៅទៅសួរសាកអញ្ចេះអញ្ចោះភ័យខ្លួនរត់ចូលព្រៃទៀត ។

វណ្ណៈ៖ អញ្ចឹងពេលពូឈប់រៀនហើយពូនៅក្នុងភូមិទេ?

ឆ្នូវៈ បាទ!

វណ្ណៈ៖ នៅក្នុងភូមិហ្នឹងធ្វើអី?

ឆ្នូវៈ នៅក្នុងភូមិធ្វើជាប្រជាជនហ្នឹង ។

វណ្ណៈ៖ ឈប់រៀននៅក្នុងភូមិជួយធ្វើការឪពុកម្ដាយ?

ឆ្នូវៈ បាទ!

វណ្ណៈ៖ អញ្ចឹងបន្ទាប់មកទៀតពូថាធ្វើឈ្លបក្នុងភូមិធ្វើអីហ្នឹងក្នុងឆ្នាំណា?

ឆ្នូវៈ អាហ្នឹងឆ្នាំ៧០ហើយ រដ្ឋប្រហារហើយ ប៉ុល ពតចូលភូមិហើយ ។

វណ្ណៈ៖ ធ្វើឈ្លបភូមិហ្នឹងធ្វើរដ្ឋប្រហារទម្លាក់សម្ដេចសីហនុហើយណ៎?

ឆ្នូវៈ បាទ!

វណ្ណៈ៖ ពេលពូចូលកាលឆ្នាំ៧០ហ្នឹង ពូចូលតាមការអំពាវនាវរបស់សម្ដេចឬក៏អត់ទេកាលហ្នឹងគ្រាន់តែចូលៗតាមគ្នាតាមអីអញ្ចឹងទៅ ដោយសារយើងឃើញខាងលន់ នល់រដ្ឋប្រហារទម្លាក់សម្ដេចអញ្ចឹងទៅយើងមានការឈឺចាប់ហើយចង់ទាមទារឲ្យសម្ដេចកាន់អំណាចវិញអញ្ចឹង អាហ្នឹងកាលហ្នឹងដោយសារអញ្ចឹងឬក៏ពូគិតឃើញយ៉ាងម៉េច?

ឆ្នូវៈ អាហ្នឹងយើងវាធ្វើអញ្ចឹងហើយ នឹកឃើញថាបើទម្លាក់សម្ដេចសីហនុស្រុកទេសយើងអត់មានបានរីកអីត្រឹមត្រូវទេ ព្រោះថាលន់ នល់ចូលខាងនោះ ដល់ពេលអញ្ចឹងក្រោកឡើងតស៊ូ ។

វណ្ណៈ៖ អញ្ចឹងពូគិតថាទម្លាក់សម្ដេចសីហនុស្រុកទេសយើងអត់សុខសាន្ដ?

ឆ្នូវៈ អត់សុខសាន្ដទេ ។

វណ្ណៈ តើពេល៧០,៧១,៧២ហ្នឹងពូនៅ..?

ឆ្នូវៈ នៅធ្វើឈ្លបភូមិហ្នឹង ។

វណ្ណៈ ពី៧០ដល់៧៥?

ឆ្នូវៈ ៧៥,៧៧បេញ ។

វណ្ណៈ អញ្ចឹងពូពី៧០ដល់៧៧ពូធ្វើឈ្លបភូមិ?

ឆ្នូវៈ បាទ!

វណ្ណៈ ខ្ញុំចង់សួរពីឆ្នាំ៧០ដល់៧៥ហ្នឹង នៅខាងកំពតហ្នឹងមានទម្លាក់គ្រាប់បែកទេ?

ឆ្នូវៈ ទម្លាក់ ។

វណ្ណៈ ទម្លាក់ដែរ?

ឆ្នូវៈ ទម្លាក់ឡើងចង់រង្គើផ្ទះ ។

វណ្ណៈ ដល់៧០ប៉ុន្មានបានឈប់ទម្លាក់គ្រាប់បែក?

ឆ្នូវៈ ដូចជាឆ្នាំ៧៣ ។

វណ្ណៈ តើទម្លាក់គ្រាប់បែកហ្នឹងពូមានដឹងសង្កេតឃើញថាមានផ្ទះអ្នកស្រុកត្រូវឆេះ ហើយមានស្លាប់មនុស្សដែរទេ?

ឆ្នូវៈ មាន ។

វណ្ណៈ មានស្លាប់មនុស្សដែរ?

ឆ្នូវៈ មាន ។

វណ្ណៈ ផ្ទះសម្បែងអីមានឆេះដែរ?

ឆ្នូវៈ ឆេះ ហើយវត្តវ៉ាអីហ្នឹងឆេះ ។

វណ្ណៈ មានឆេះវត្តទៀត?

ឆ្នូវៈ ឆេះ វត្តអន្តឡើងពេញហ្នឹងដោយសារគ្រាប់បែក ។

វណ្ណៈ ចុះមានដឹងទេថាហេតុអីបានជាអាមេរិកកាំងទម្លាក់គ្រាប់បែកមកលើប្រទេសយើងអញ្ចឹង ដោយសារមូលហេតុអីបើតាមពូស្វែងយល់?

ឆ្នូវៈ បើតាមខ្ញុំស្វែងយល់មកពីគេចង់ជួយលន់ នល់ ហើយមួយទៀតមកពីវាចង់បំផ្លាញយួន ។

វណ្ណៈ អញ្ចឹង?

ឆ្នូវៈ យួនវាចូលមកដែរកាលហ្នឹង ។

វណ្ណៈ យួនចូលមកដែរ?

ឆ្លូវៈ យួនចូលមកដែរមកជ្រកកោនក្នុងប្រទេសយើងដែរ ធ្វើសង្គ្រាមជាមួយវៀតណាមខាងត្បូង ហើយចេញមករួមវ៉ៃទម្លាក់លន់ នល់ដែរ ហើយខ្មែរក្រហមហើយនឹងយួនកាលនោះត្រូវគ្នាទេ ។

វណ្ណៈ កាលហ្នឹងខាងចលនាខ្មែរក្រហមសម្តេចសីហនុម្ខាងហើយត្រូវជាមួយយួនដែរ ហើយខាងលន់ នល់ក៏ទៅពឹងយួនដែរ កាលនោះយួនធៀវគី ហើយខាងខ្មែរក្រហមក៏ទៅពឹងយួនដែរ ។

ឆ្លូវៈ ពឹងយួនកម្មុយនិស ។

វណ្ណៈ ហ្នឹងអើយ តាមពិតយើងពឹងគេទាំងអស់គ្នា អ៊ីដែលខាតបង់គឺខ្មែរយើង សង្គ្រាមសម្លាប់គ្នា ។

ឆ្លូវៈ បាទ!

វណ្ណៈ ពូយល់ឃើញយ៉ាងម៉េចដែរពេលដែលប្រទេសកំពុងតែមានសង្គ្រាមអញ្ចឹង ពូគិតថាតើវាអាចប៉ះពាល់ជីវិតមនុស្ស ធ្វើឲ្យប្រជាជនខាតបង់យ៉ាងម៉េចដែរ?

ឆ្លូវៈ ខាតបង់ទាំងពេលវេលារកស៊ី សំខាន់ពេលវេលារកស៊ី ហើយនឹងបាត់បង់អាយុជីវិតប្រជាជនគ្រប់ស្រទាប់វណ្ណៈទាំងអស់ ។

វណ្ណៈ ចុះពូនៅធ្វើឈ្លបធំនៅភូមិរហូតប្តក៏បានទៅស្រុកអីដែរ?

ឆ្លូវៈ ធ្វើនៅឃុំ ។

វណ្ណៈ ធ្វើនៅឃុំ?

ឆ្លូវៈ បាទ!

វណ្ណៈ ហើយឆ្នាំណាបានទៅឃុំ?

ឆ្លូវៈ ទៅឆ្នាំ៧៦ ហើយឆ្នាំ៧៧បានគេបញ្ជូនខ្ញុំទៅឃុំ ។

វណ្ណៈ ចុះពូកាលហ្នឹងដូចថាគណៈស្រុកគណៈតំបន់អីពូមានស្គាល់ទេនៅកំពតណ៎ា ពីណាគេ?

ឆ្លូវៈ វាច្រើនពេកខ្ញុំចាំមិនអស់ទេ ហើយផ្លាស់រហូតព្រោះឆ្នាំមួយក្បត់ៗ ហើយឡើងច្រើនដំណាក់ណាស់ ។

វណ្ណៈ ចុះពូគិតថាកាលហ្នឹងអាដកចុះដកឡើងហ្នឹង ។

ឆ្លូវៈ កាលហ្នឹងគណៈតំបន់មានតាចាប ។

វណ្ណៈ មានតាចាប ហើយពូមានដឹងថាតាចាបគេចាប់ខ្លួនទេ?

ឆ្លូវៈ ខ្ញុំដឹង ព្រោះកាលហ្នឹងខ្ញុំផ្លាស់មកជាមួយតាចាប ។

វណ្ណៈ កង ចាបមែន?

ឆ្លូវៈ កង ចាប ។

វណ្ណៈ គាត់គណៈតំបន់មែន?

ឆ្លូវៈ បាទ!

វណ្ណៈ ហើយមានពីណាគេទៀតពូ?

ឆ្លូវៈ មានតារិន ។

វណ្ណៈ ស្អីរិន?

ឆ្លូវៈ ភួង រិន ។

វណ្ណៈ ភួង រិន?

ឆ្លូវៈ បាទ! រិន បងប្អូនតារុំនេះ រុំមេទ័ពកងពលធំយើងនេះ រុំហ្នឹងនៅរៀនជាមួយខ្ញុំ ។

វណ្ណៈ ហើយឥលូវភួង រិននៅហ្នឹងដែរ?

ឆ្លូវៈ គេកាន់កងពលទីប៉ុន្មានទេ ។

វណ្ណៈ ភួង រិនហ្នឹងគាត់មានឋានៈជាអីកាលជំនាន់៣ឆ្នាំហ្នឹង?

ឆ្លូវៈ គាត់មានឋានៈជាអនុតំបន់ ។

វណ្ណៈ តំបន់ប៉ុន្មាន?

ឆ្លូវៈ តំបន់៣៥ ។

វណ្ណៈ នៅកំពត?

ឆ្លូវៈ នៅកំពត ។

វណ្ណៈ អញ្ចឹងសព្វថ្ងៃនេះភួង រិនគាត់រស់នៅណា?

ឆ្លូវៈ ដឹងអីគេថាក្បត់ៗ ។

វណ្ណៈ អញ្ចឹងភួង រិនហ្នឹងគេចាប់ដែរ?

ឆ្លូវៈ ចាប់ ។

វណ្ណៈ ចាប់ជាមួយកង ចាប?

ឆ្លូវៈ បាទ! កុំអីចាប់ដល់ខ្ញុំទៀតហើយ កុំតែបានយួនចូលស្រុកហ្នឹង ហើយខ្ញុំនៅតែប្រហែលមួយខែទៀតទៅទៀតហើយមើលទៅ ។

វណ្ណៈ កាលហ្នឹងខ្មែរក្រហមចាប់ផ្ដើមសម្លាប់គ្នាហើយ ចាំមើលដំបូងឡើយខ្មែរក្រហមចាប់មន្ត្រីរាជការដែលធ្លាប់ធ្វើបាបប្រជាកសិករអញ្ចឹងយកទៅសម្លាប់ចោល ដល់ពេលស្រង់មន្ត្រីរាជការអស់ទៅចាប់ផ្ដើមសម្លាប់គ្នាឯងទៀត ចុះពូគិតឃើញយ៉ាងម៉េចដែរបើតាមយោបល់របស់ពូវិញ តើថ្នាក់លើដែលមានរចនាសម្ព័ន្ធធ្វើអញ្ចឹង តើពូដែលខំតស៊ូស្មោះជាមួយអង្គការ ហើយក្រោយមកអង្គការរកចាប់ខ្លួនអញ្ចឹងតើពូគិតឃើញយ៉ាងម៉េចដែរ?

ផូវៈ	អយុត្តិអធម៌ណាស់ ខ្ញុំនឹកឃើញខ្លួនខ្ញុំថា ខ្ញុំបើស្លាប់ហ្នឹងបម្រើប្រជាជនខ្ញុំអត់ស្ដាយទេ ព្រោះខ្ញុំអត់មានរឿងអីគួឲ្យក្បត់សោះ ភាគច្រើនអ្នកស្លាប់ច្រើនតែអ្នកស្លូតត្រង់ហ្នឹងហ្នង ។

វណ្ណៈ	ខ្ញុំធ្លាប់ជាមួយតាមួយគាត់នៅស្រុក ឈ្មោះតាផែង ពូមានស្គាល់ទេ?

ផូវៈ	តាដែនអី?

វណ្ណៈ	ហ្នឹងអើយ ។

ផូវៈ	អ៊ំស្គាល់ហើយតាដែនប៊ុនវ៉ាហារហ្នឹង?

វណ្ណៈ	ហ្នឹងអើយគាត់ល្អិតទេ ។

ផូវៈ	ហ្នឹងអើយគាត់ល្អិតទេ គាត់នៅជិតផ្ទះខ្ញុំហ្នឹង ។

វណ្ណៈ	គាត់ថាកាលហ្នឹងគេចាប់កង ចាបហ្នឹងគាត់ភ័យខ្លួនដែរ មួយថ្ងៃៗគាត់... ។

ផូវៈ	គាត់ធ្វើធំដែរតើ ។

វណ្ណៈ	ហ្នឹងអើយគាត់ធ្វើធំ គាត់ធ្វើប្រហែលជាគណៈស្រុកអីដែរ ។

ផូវៈ	តែតាំងពីបែកមកមិនដឹងគាត់ឡើងទៅដល់ណាទេ ។

វណ្ណៈ	តែឥលូវគាត់នៅស្រុកកំណើត គាត់ចាស់ហើយឥលូវ អាយុប្រហែលជា៧០ជាងហើយ ។

ផូវៈ	ចាស់ហើយ ព្រោះគាត់បងខ្ញុំទៀត ។

វណ្ណៈ	តែគាត់ថា គាត់និយាយជាមួយខ្ញុំថាក្មួយអើយធ្វើការៗគ្រាន់តែឃើញសំបុត្រមកថាចាប់កង ចាបអីហ្នឹងគាត់ថាគាត់ភ្ញាក់ខ្លួនព្រោះនៅក្បែៗអញ្ចឹង គាត់ថាមិនដឹងថ្ងៃណាដល់វេនគាត់ទេ គាត់ថាអញ្ចឹងណា៎ ដល់ក្រោយមករំដោះទៅបានរួចខ្លួនទៅ ។

ផូវៈ	ដែលគេហៅអាចារ្យដែនៗហ្នឹង?

វណ្ណៈ	បាទ!

ផូវៈ	គេហៅតែអាចារ្យដែនហ្នឹង ។

វណ្ណៈ	កាលជំនាន់ពាន្លាំគេហៅអាចារ្យដែនដែរ?

ផូវៈ	បាទ! ព្រោះគាត់ចេះខាងធម៌អារដូចថាវ៉ាល្អិតគួសមរបស់គាត់ដែរ ។

វណ្ណៈ	ហើយតាហ្នឹងគាត់ទំនងរហ័ស?

ផូវៈ	បាទ!

វណ្ណៈ	ហើយចុះពូកាលចាប់កង ចាបពូមានដឹងដែរមែនទេ?

ផូវៈ	ខ្ញុំដឹងតែខ្ញុំអត់នៅជាមួយទេ ។

វណ្ណៈ	កង ចាបហៅដូ ចេតហ្នឹងទេមែនទេ ឈ្មោះគាត់ពីរហ្នឹងប៉ុក្ដដូ ចេតផ្សេង?

ផ្លូវៈ កង ចាបផ្សេង ។

វណ្ណៈៈ ចុះពូកាលចាប់ហ្នឹងពូមានដឹងថាខាងណាអ្នកចាប់ទេ?

ផ្លូវៈ ខ្ញុំមិនដឹងទេ ព្រោះគាត់នៅតំបន់កងធំ នៅខេត្ត ។

វណ្ណៈៈ ចុះពូ ពូនៅឈ្លបឃុំហ្នឹងតើមេពូពីណាគេ?

ផ្លូវៈ ខ្ញុំភ្លេចឈ្មោះបាត់ហើយ ។

វណ្ណៈៈ ភ្លេចឈ្មោះហើយ?

ផ្លូវៈ បាទ! ខ្ញុំស្គាល់តែអនុ ។

វណ្ណៈៈ អនុឈ្មោះអី?

ផ្លូវៈ ឈ្មោះ ណូត តែមិនដឹងឈ្មោះអីណូតទេ ។

វណ្ណៈៈ ណូត ហ្នឹងមានឋានៈជាអីគេ?

ផ្លូវៈ ដូចជាអនុប្រធាន ។

វណ្ណៈៈ អនុប្រធានកងសន្តិសុខឬអនុប្រធានអីគេកាលហ្នឹង ។

ផ្លូវៈ កងឈ្លបមិនមែនសន្តិសុខទេ ឈ្លបសម្រាប់ការពារក្នុងភូមិ ។

វណ្ណៈៈ អញ្ចឹងពូដូចថានៅក្នុងសម័យហ្នឹងដែរដូចថាការចាប់ខ្លួន ប្រជាជនអត់អាហារអីហ្នឹងពូដឹងទេ?

ផ្លូវៈ ដឹងតើ ។

វណ្ណៈៈ ដឹងដែរណោះ?

ផ្លូវៈ បាទ!

វណ្ណៈៈ ប្រជាជនអត់មានអាហារហូបគ្រប់គ្រាន់អីពូដឹងដែរណោះ?

ផ្លូវៈ ដឹង!

វណ្ណៈៈ ពូគិតថាអាហ្នឹងជាកំហុសរបស់អ្នកដឹកនាំពីលើឬក៏កំហុសត្រឹមឈ្លប ត្រឹមគណៈកងធំអញ្ចឹង?

ផ្លូវៈ វាមានពីរយ៉ាង ម៉្យាងវាមានការច្នៃប្រឌិតដែរ ខ្ញុំមិនកាន់ដើងទេ ដូចថា១០ហើយយើងបន្ថែមពីលើ៥ទៀតណាំ ។

វណ្ណៈៈ អញ្ចឹងពូគិតថាកំហុសអ្នកលើខ្លះអ្នកក្រោមខ្លះ?

ផ្លូវៈ បាទ!

វណ្ណៈៈ អញ្ចឹងដូចពូនៅរចនាសម្ព័ន្ធឈ្លបភូមិ ឈ្លបឃុំអញ្ចឹងតើរាល់ពេលដែលចង់ទៅយកអ្នកណាម្នាក់អញ្ចឹងគឺមានសំបុត្រស្នាមមកពីខាងលើឬក៏មិនមានទេ ឬក៏គេបញ្ជាមកពីខាងលើ?

ផ្លូវៈ គេបញ្ជាមកពីខាងលើ ។

វណ្ណៈ  មកពីត្រឹមណា  ស្រុកឬក៏មានឈ្មោះឲ្យមកតែម្ដង?

ឆ្នូវៈ    មានឈ្មោះឲ្យតែម្ដង ។

វណ្ណៈ  យើងខុបមាថាយើងគេប្រើយើងត្រូវតែទៅ?

ឆ្នូវៈ    ហ្នឹងអើយ  បើយើងមិនទៅធ្វើយើងកុនហើយ ។

វណ្ណៈ  អញ្ចឹង?

ឆ្នូវៈ    ហ្នឹងអើយ ។

វណ្ណៈ  ចុះបើយើងប្រកែកថាយើងមិនហ៊ានទៅទេ?

ឆ្នូវៈ    អត់បានទេ  មិនថាតែបងប្អូនទេសូម្បីតែឪពុកក៏យើងត្រូវតែទៅដែរ ។

វណ្ណៈ  អញ្ចឹង?

ឆ្នូវៈ    យើងត្រូវតែធ្វើ ។

វណ្ណៈ  ឲ្យតែមានឈ្មោះយើងត្រូវតែចាប់ហើយ?

ឆ្នូវៈ    បាទ!

វណ្ណៈ  ចុះបើសិនជាឪពុកពូ  ពូហ៊ានទេ?

ឆ្នូវៈ    ខ្ញុំមិនហ៊ានទេ  តែបើសិនជាអញ្ចឹងពិតមែនខ្ញុំប្រគល់ឲ្យគេហើយ ។

វណ្ណៈ  ប៉ុន្តែមិនដឹងធ្វើម៉េចទេត្រូវតែចាប់ហើយណោះ?

ឆ្នូវៈ    ត្រូវតែចាប់ ។

វណ្ណៈ  អញ្ចឹងមានបញ្ជាពីស្រុកមកណោះ?

ឆ្នូវៈ    បាទ!

វណ្ណៈ  មានឈ្មោះមកហ្នឹង?

ឆ្នូវៈ    ហ្នឹងអើយ ។

វណ្ណៈ  ទោះបីបងប្អូនសាច់ញាតិក៏អត់អាចអធ្យាស្រ័យបានដែរ?

ឆ្នូវៈ    អត់បានទេ ។

វណ្ណៈ  ចុះពូគិតថានៅខាងហ្នឹង  នៅហ្នឹងអត់មាននារីតីទេ?

ឆ្នូវៈ    តែនៅកំពតមាននារីតីហើយ ។

វណ្ណៈ  មាននារីតីដែរណោះ?

ឆ្នូវៈ    ព្រោះវាចាប់តាំងពីភូមិភាគ.... ។

វណ្ណៈ  ចាប់ពួននារីតីដែរ  អញ្ចឹងតាម៉ុកគ្រប់គ្រងដែរ?

ផូវៈ តាម៉ុក មានកំពង់ស្ពឺ តាកែវ កំពតនារតីហើយ ។

វណ្ណៈ អញ្ចឹង?

ផូវៈ ហ្នឹងអើយ ។

វណ្ណៈ អញ្ចឹងមិនមែនសំដៅតែតាកែវមួយទេនារតី?

ផូវៈ មិនមែនតែតាកែវមួយទេ មានដល់ទៅ៣ខេត្តណោះ ។

វណ្ណៈ អញ្ចឹងមានកំពត តាកែវ កំពង់ស្ពឺគេហៅភូមិភាគនារតី?

ផូវៈ បាទ!

វណ្ណៈ គ្រប់គ្រងដោយតាម៉ុក?

ផូវៈ បាទ!

វណ្ណៈ អញ្ចឹងពូ បេតអីគ្រាន់ជាគណៈតំបន់ទេ?

ផូវៈ គណៈតំបន់ ។

វណ្ណៈ អញ្ចឹងមូលហេតុអីបានជាគេចាត់តាំងអ៊ីមកកំពង់ធំទៀត?

ផូវៈ អាហ្នឹងជាបញ្ហាពីលើមកដូចថាត្រូវផ្លាស់ប្តូរគ្នាអញ្ចឹងហ្នង ។

វណ្ណៈ អ៎គេត្រូវតែផ្លាស់ប្តូរគ្នាអញ្ចឹង?

ផូវៈ បាទ!

វណ្ណៈ ពូខ្ញុំចង់ដឹងទៀតថានៅកំពតហ្នឹងពូមានដឹងថាគេមានការចាប់មនុស្សច្រើនទេ?

ផូវៈ ច្រើន ។

វណ្ណៈ ចុះមន្ទីរសន្តិសុខនៅកន្លែងណាខ្លះនៅកំពត?

ផូវៈ មន្ទីរសន្តិសុខមាននៅទំនប់ស្ទឹងភា ។

វណ្ណៈ មានតែមួយកន្លែងទេពូ អត់មានកន្លែងណាផ្សេងទៀតទេ?

ផូវៈ អត់មានទេ តែក្រែងលោគេមានកន្លែងណាទៀតខ្ញុំមិនដឹងទេ ។

វណ្ណៈ តែពូបានដឹងតែមួយកន្លែងទេ?

ផូវៈ បាទ!

វណ្ណៈ អញ្ចឹងដល់៧៧ពូមកនៅកំពង់ធំវិញ ពូការហើយមែនទេ?

ផូវៈ ការរួចហើយ ។

វណ្ណៈ ពូការឆ្នាំណា?

ផូវៈ ការឆ្នាំ៧៧ ។

វណ្ណៈ ៧៧ការហើយគេផ្លាស់ហ្នឹងណោះ?

ឆ្នូវៈ បាទ!

វណ្ណៈ ចុះពូពេលការហ្នឹងពូមានជ្រើសរើសយកគ្រួសារដែរ ឬក៏អង្គការចាត់តាំង?

ឆ្នូវៈ អត់ទេ កាលហ្នឹងស្ទើរព្រោះកាលហ្នឹងឪពុកម្ដាយរៀបចំឲ្យ ។

វណ្ណៈ ៧៧ហើយ កំពុងពេញខ្មែរក្រហមហើយអត់មានការមានភ្លេងភ្លាត់អីទេ គឺខ្មែរក្រហមរៀបឲ្យ?

ឆ្នូវៈ មិនមែនទេ ។

វណ្ណៈ ការតាំងពីណាមកទេអី?

ឆ្នូវៈ អត់ទេ បានមួយឆ្នាំប្រពន្ធខ្ញុំមានទម្ងន់អាមួយនោះ ដូចជា៧៣ ។

វណ្ណៈ អ៉កាលជិនាន់៧៣?

ឆ្នូវៈ ហ្នឹងអើយ ។

វណ្ណៈ ការឆ្នាំ៧៣នៅមានភ្លេងការនៅឡើយទេ ។

ឆ្នូវៈ ហើយកាលមកនៅកំពង់ធំប្រពន្ធខ្ញុំគេឆ្លងទន្លេ ។

វណ្ណៈ ចុះកាលមកនៅកំពង់ធំប្រពន្ធអត់មកជាមួយទេ?

ឆ្នូវៈ អត់មកទេ ទាល់តែបានមួយខែពីរខែបានគេមកតាម ។

វណ្ណៈ ចុះកាលពូមកនៅកំពង់ធំហ្នឹង និយាយពី៧៧រហូតដល់៧៩រត់យួនហ្នឹងហ្នង?

ឆ្នូវៈ បាទ!

វណ្ណៈ ចុះមកដល់កំពង់ធំតើពូធ្វើអីវិញ?

ឆ្នូវៈ ធ្វើប្រធានភូមិ ។

វណ្ណៈ ធ្វើប្រធានភូមិរហូត?

ឆ្នូវៈ ហ្នឹងអើយ ។

វណ្ណៈ ប្រធានភូមិឬក៏មានប្រធានសហករណ៍ផ្សេង?

ឆ្នូវៈ ប្រធានភូមិ ។

វណ្ណៈ ហើយប្រធានសហករណ៍ផ្សេងទៀត?

ឆ្នូវៈ ផ្សេង ។

វណ្ណៈ គណៈសហករណ៍ផ្សេងទៀត?

ឆ្នូវៈ បាទ!

វណ្ណៈ ពូកាលហ្នឹងពូនៅប្រធានភូមិអីគេ ភូមិអីគេហើយកាន់ប៉ុន្មានភូមិ មានភូមិអីខ្លះដែលពូចាំ?

នួវៈ មានភូមិត្រឡោក ។

វណ្ណៈ ឃុំអី?

នួវៈ អត់ចាំទេ ។

វណ្ណៈ ហើយប៉ុន្មានភូមិបានមានសហករណ៍មួយ?

នួវៈ មាន៣ភូមិ អ៎មានឃុំបារាយណ៍ ។

វណ្ណៈ អញ្ចឹងទាល់តែ៣ភូមិបានមានសហករណ៍មួយណោះ?

នួវៈ បាទ!

វណ្ណៈ ចុះកាលហ្នឹងប្រជាជនទៅធ្វើស្រែចំការ លើកទំនប់ លើកប្រឡាយអីធម្មតា?

នួវៈ បាទ!

វណ្ណៈ ហើយកាលនៅកំពង់ធំតើការហូបចុកអីមានខ្វះខាតដាច់នៅកំពតឬក៏កំពតខ្វះដាច់?

នួវៈ ចាញ់នៅកំពតទេ នៅកំពតគ្រាន់បើដាច់ ។

វណ្ណៈ ខ្វះខាតដាច់នៅកំពតទៀត?

នួវៈ បាទ! ស្រូវធ្វើបានតែមិនដឹងដាក់ទៅណា ។

វណ្ណៈ បាទ!

នួវៈ ខ្ញុំមិនដែលហូបដើមចេកទេ តែដល់ពេលមកនៅកំពង់ធំហូបដើមចេក ។

វណ្ណៈ ហើយដូចថាកាលជំនាន់ខ្មែរក្រហមហ្នឹងទាំងប្រជាជន ទាំងអ្នកធ្វើការ ហើយទាំងឈ្លបក៏ដោយ ដូចជាគណៈកងក៏ដោយគឺហូបចុកស្មើរគ្នា អត់មានលើសរបបលើសអីទេ ដូចថាគេមេគេហូបបាយសុទ្ធ ហើយប្រជាជនហូបបបរទេ?

នួវៈ អត់ទេ គឺហូបស្មើរគ្នា ។

វណ្ណៈ បើគល់ចេកគឺគល់ចេកទាំងអស់គ្នា?

នួវៈ បាទ!

វណ្ណៈ ចុះពូមកហ្នឹងបានប៉ុន្មានខែបានប្រពន្ធហើយនឹងកូនចៅរបស់ពូទៅ?

នួវៈ ៣ខែ ។

វណ្ណៈ ៣ខែបានទៅនៅជុំគ្នាទៅ?

នួវៈ បាទ!

វណ្ណៈ កាលដែលពូមកនៅកំពង់ធំហ្នឹងពីណាគេជាអ្នកចាត់តាំងពូមក?

ឆ្លូវៈ គណៈឃុំគេ ។

វណ្ណៈៈ មិនមែនតាម៉ុកមកចាត់តាំងទេ?

ឆ្លូវៈ អត់ទេ គណៈឃុំ គេអត់មានប្រាប់ថាទៅណាមកណាទេ បើគេយកទៅវៃចោលក៏មិនដឹង ។

វណ្ណៈៈ គេហៅឡើងឡានទៅ?

ឆ្លូវៈ បាទ!

វណ្ណៈៈ គ្នាច្រើនទេកាលគេហៅឡើងឡានហ្នឹង?

ឆ្លូវៈ កាលហ្នឹងប្រហែល២០០នាក់ ។

វណ្ណៈៈ ២០០នាក់មកកំពង់ធំហ្នឹង ហើយបែងចែកថាពីណាធ្វើប្រធានភូមិ ពីណាធ្វើប្រធានឃុំទៅ អ្នកខ្លះធ្វើឈ្លប ហើយអ្នកខ្លះធ្វើប្រធានសហករណ៍ទៅ?

ឆ្លូវៈ ហ្នឹងអើយ ។

វណ្ណៈៈ គេបែងចែកតាមឋានៈមែនពូ?

ឆ្លូវៈ បាទ!

វណ្ណៈៈ ចុះពូនៅកំពង់ធំ៧៧,៧៨ហ្នឹងនិយាយទៅសឹងតែទូទាំងប្រទេសហើយដែលលំបាកហ្នឹង ដែលគេសម្រិតសម្រាំងយកមនុស្សទៅវៃចោល?

ឆ្លូវៈ អាហ្នឹងចុងកន្ទុយហើយ ។

វណ្ណៈៈ បាទ! ហើយពូមកនៅកំពង់ធំហ្នឹងពូមានដឹងថាមានការសម្លាប់មនុស្សកាន់តែច្រើនប្លុក៏ម៉េចដែរ?

ឆ្លូវៈ ខ្ញុំទៅហ្នឹងគេចាប់ចង់អស់ហើយ ។

វណ្ណៈៈ គេចាប់ចង់អស់ហើយ?

ឆ្លូវៈ បាទ!

វណ្ណៈៈ ហើយចុះមានប្រជាជនស្លាប់ដោយសារអត់អាហារទេ?

ឆ្លូវៈ កាលហ្នឹងវាមានខ្លះ ព្រោះគេធ្វើការហត់ហេវ ហូបមិនគ្រប់គ្រាន់ ហូបតែបបរហើយនឹងដើមចេកប៉ុណ្ណោះ ។

វណ្ណៈៈ អញ្ចឹងនៅខាងកំពង់ធំពូមានដឹងថាពីណាគេគ្រប់គ្រងទេ?

ឆ្លូវៈ អ្នកគ្រប់គ្រងកាលពីមុនឈ្មោះទី ។

វណ្ណៈៈ ទី ហ្នឹងគាត់ធ្វើអី?

ឆ្លូវៈ គាត់គណៈស្រុក ប៉ុន្តែក្រោយមកគេចាប់គាត់ ។

វណ្ណៈៈ គេចាប់គាត់?

ឆ្លូវៈ បាទ!

វណ្ណៈ ទី ហ្នឹងឡើងពីណាមកវិញ?

ឆ្លូវៈ ឡើងពី ប៉ូច ។

វណ្ណៈ ពូមានដឹងថាតា ប៉ូច នៅរស់ទេសព្វថ្ងៃ?

ឆ្លូវៈ មិនដឹងស្លាប់ឬក៏រស់ទេ ព្រោះគាត់នៅអន្លង់វែងនុ៎ះ ។

វណ្ណៈ តាប៉ូចជាអ្នកមកពីកំពង់ធំដែរឬក៏អ្នកមកពីខាងណា តាប៉ូចហ្នឹងអ្នកតាកែវ?

ឆ្លូវៈ គាត់ប្រហែលជាអ្នកកំពង់ស្ពឺ ។

វណ្ណៈ ហើយកាលតាប៉ូចកាលគាត់កាន់ហ្នឹងមានការតឹងតែងដែរឬក៏អត់ទេ?

ឆ្លូវៈ កាលហ្នឹងវាធូរតិចដែរ ដូចថាវាមានអាមាគាំមួយ ។

វណ្ណៈ មាគាំហ្នឹងឆ្នាំណាបានចេញ?

ឆ្លូវៈ កាលឆ្នាំ៧៩យួនចូលមែនទេ?

វណ្ណៈ បាទ!

ឆ្លូវៈ អញ្ចឹងឆ្នាំ៧៨ បន្ធូរបន្ថយសម្រិតសម្រាំង ។

វណ្ណៈ អង្គការបន្ធូរបន្ថយរៀបចំច្បាប់ ការសម្លាប់មនុស្ស ហ្នឹងឲ្យអាហារគ្រប់គ្រាន់ ហូបគ្រាប់គ្រាន់ ។

ឆ្លូវៈ បាទ!

វណ្ណៈ អញ្ចឹងកាល៧៨ហ្នឹងគ្រាន់តែផ្សព្វផ្សាយឬក៏មានចេញជាលាយល័ក្ខអក្សរ?

ឆ្លូវៈ កាលហ្នឹងគ្រាន់តែផ្សព្វផ្សាយទេ អត់មានលាយល័ក្ខអក្សរទេ ។

វណ្ណៈ អញ្ចឹងកាល៧៨ហ្នឹងផ្សព្វផ្សាយខាងបន្ធូរបន្ថយ ឲ្យប្រជាជនហូបគ្រាន់បើបន្តិចទៅ?

ឆ្លូវៈ បាទ!

វណ្ណៈ ហើយតើថ្នាក់ក្រោមហ្នឹងធ្វើតាមឬក៏មិនធ្វើតាមទេ នៅតែឲ្យប្រជាជនអត់ឃ្លានរហូត?

ឆ្លូវៈ ធ្វើ តែកន្លែងខ្លះគ្នាអត់ខ្លាំងពេក ដូចថាភូមិខ្លះអីអញ្ចឹងណ៎ា អាខ្លះរត់ទៅរកទាក់ទងភូមិគេផ្សេង អញ្ចឹង ទៅរកពីគេហ្នឹងមក ។

វណ្ណៈ ចុះបន្ទាប់ពីតាប៉ូចមានពីណាទៀតទេ?

ឆ្លូវៈ អត់ដឹងទេ ។

វណ្ណៈ ចុះអនុតាប៉ូចអីនោះ ពូមានស្គាល់ទេ?

ឆ្លូវៈ អនុ អ៊ំនឹកឃើញហើយឈ្មោះតាពីន ។

វណ្ណៈ ចុះតាពីនគាត់នៅទេរាល់ថ្ងៃ?

ឆ្លូវៈ គាត់នៅស្រុកអីគេជាប់ក្រចេះ ។

វណ្ណៈ បាទ! តាពីន?

ឆ្លូវៈ មិនមែនទេឈ្មោះតាពិន ។

វណ្ណៈ បន្ទាប់ពីតាប៉ូច មានតាពិន?

ឆ្លូវៈ បាទ!

វណ្ណៈ ចុះពូដូចថាធ្លាប់ធ្វើការនៅហ្នឹង ហើយតាប៉ូចគាត់ជាមនុស្សមួយម៉ឺងម៉ាត់ដែរឬក៏យ៉ាងម៉េច?

ឆ្លូវៈ គាត់មិនជាអ្នកកោងកាចអីទេ ។

វណ្ណៈ បាទ!

ឆ្លូវៈ គាត់សុភាពរាបសារណាស់ ។

វណ្ណៈ គាត់មិនសាហាវ មិនបញ្ជាឲ្យយកមនុស្សទៅសម្លាប់ចោលទេ?

ឆ្លូវៈ គាត់មុននឹងធ្វើអីគាត់ច្រើនតែហៅសមាជិកមកពិភាក្សាគ្នា ដូចថាត្រូវចាប់អានេះចាប់អានោះ យើងត្រូវធ្វើយ៉ាងម៉េច ឥលូវយើងថាអញ្ចេះអញ្ចោះយើងបន្តូរវាទៅណា៎ ។

វណ្ណៈ គាត់ថាអញ្ចឹងទៀត?

ឆ្លូវៈ បាទ! ហើយគាត់ថាមុនហ្នឹងធ្វើអីមើលផង គាត់មិនមែនចេះតែបញ្ជាធ្វើទទឹងទើសទេ ។

វណ្ណៈ អញ្ចឹងពេលគេបញ្ជាមកគាត់ហៅប្រធានភូមិទាំងអស់មកពិភាក្សា?

ឆ្លូវៈ ហ្នឹងអើយ ប្រធានភូមិយើងហ្នឹងមកពិភាក្សា គាត់ធ្វើម៉ត់ចត់ដែរ ។

វណ្ណៈ អញ្ចឹងមិនមែនធ្វើតែគាត់ទេមែនទេ?

ឆ្លូវៈ បាទ!

វណ្ណៈ បើសម្រេចថាលើកលែងអាហ្នឹងគាត់លើកលែងទៅ?

ឆ្លូវៈ បាទ! គាត់សុទ្ធតែពិភាក្សាថាមើលជួយគិតគ្នាមើលថាវាជាប់ខ្សែរយៈអ្នកណា ពិនិត្យឲ្យម៉ត់ចត់បន្តិច ដល់ពិនិត្យទៅមើលទៅដូចថាវាគ្មានជាប់ខ្សែអ្នកណាទេ យើងលុបចោលខ្លះទៅ ។

វណ្ណៈ អញ្ចឹង,

ឆ្លូវៈ ហ្នឹងអើយ

វណ្ណៈ អ្នកណាមិនជាប់ពាក់ព័ន្ធមិនចាប់ទេ?

ឆ្លូវៈ បាទ!

វណ្ណៈ អញ្ចឹងខ្ញុំចង់សន្មែបរបបពៅនឆ្នាំប៉ុណ្ណឹង ហើយចង់សួរឆ្នាំ១៩៧៩ពេលដែលវៀតណាមចូលមក ហេតុអីបានជាពូអត់រត់សំដៅមកស្រុកកំណើត ហើយបែជារត់មកតាមជាយដែនវិញ ។

ឆ្នូវៈ អាហ្នឹងដូចខ្ញុំបានជម្រាបពីមុនអញ្ចឹង ថាមនោគមន៍វិជ្ជាហ្នឹងម៉្យាង ហើយម៉្យាងទៀតដូចថាប្រវត្តិរបស់យួនវាជួរចត់ដែរ វាលេបទឹកដីកម្ពុជាក្រោមគេហ្នឹង ។

វណ្ណៈ ហើយពូធ្វើដំណើរតាមផ្លូវណា ហើយមកដល់ណាដំបូង?

ឆ្នូវៈ ខ្ញុំចូលព្រៃ ។

វណ្ណៈ រត់ចេញពីកំពង់ធំ?

ឆ្នូវៈ រត់ចូលព្រៃនៅភ្នំដី មានដែលស្គាល់ភ្នំដីទេ?

វណ្ណៈ ពូដែរតែមិនដែលបានទៅ ។

ឆ្នូវៈ ខ្ញុំមិនដែលទៅដែរហ្នឹង គ្រាន់ថារត់កាត់ហ្នឹង ហើយនៅក្នុងព្រៃហ្នឹងមនុស្សរាប់ម៉ឺន ហើយមនុស្សអត់ឃ្លានច្រើនណាស់ ទាំងប្រជាជនទាំងកម្លាំងទ័ពទាំងអស់ទៅស្លាប់ស្ទើរជិតពាក់កណ្ដាល ។

វណ្ណៈ ស្លាប់នៅភ្នំដីហ្នឹង?

ឆ្នូវៈ បាទ! ដោយសារអត់បាយ ហើយហ្នឹងយួនវៃចូលមន្ទីរពេទ្យហើយដុតគ្នាទាំងរស់ គ្នានៅរស់សោះហ្នឹងអត់ព្រមយកគ្នាទៅពេទ្យអត់ ដុតមន្ទីរពេទ្យហ្នឹងដុតទាំងមនុស្ស អាខ្លះចាក់ហ្នឹងចំពុះទង់ឈើគ្រុនចាញ់អីហ្នឹង ។

វណ្ណៈ អាហ្នឹងពូថាយួនដុតមន្ទីរពេទ្យសម្លាប់អីហ្នឹង ពូមានបានឃើញដែរឬក៏អត់មានបានឃើញទេ?

ឆ្នូវៈ ខ្ញុំបានឃើញតើ ព្រោះពេលហ្នឹងពួកខ្ញុំនៅហ្នឹង ។

វណ្ណៈ ចុះពេលចាក់ពូមានបានឃើញទេ?

ឆ្នូវៈ ពេលចាក់ហ្នឹងខ្ញុំឮគេថាដែរទេ ។

វណ្ណៈ ពូឮគេថា?

ឆ្នូវៈ បាទ!

វណ្ណៈ យើងអត់មានបានឃើញផ្ទាល់ភ្នែកទេ?

ឆ្នូវៈ បាទ!

វណ្ណៈ អញ្ចឹងដល់ពេលរត់ចេញពីភ្នំដីហ្នឹងទៅទៀត ពូរត់ទៅណាវិញ?

ឆ្នូវៈ ខ្ញុំមកដងរែក ។

វណ្ណៈ ទៅដងរែកនៅអន្លង់វែងហ្នឹង?

ឆ្នូវៈ ដងរែកយើងជាប់ព្រំដែនលាវ ។

វណ្ណៈ បាទ!

ឆ្នូវៈ ដែលគេហៅថា១០០១ហ្នឹង ។

វណ្ណៈ ចុះកាលនៅកំពង់ធំពូអត់មានស្គាល់តាកៅ ពក អីទេ?

ឆួរៈ ស្គាល់ ។

វណ្ណៈ កៅ ពក ហ្នឹងឋានៈគាត់ជាអីគេ ពូមានដឹងទេ?

ឆួរៈ គាត់មានតួនាទីជាគណៈភូមិភាគ ។

វណ្ណៈ តាពក កាចទេ?

ឆួរៈ បើតាមខ្ញុំមើលដូចជាមិនកាចអីប៉ុន្មានទេ តែបើគេកាចក៏ខ្ញុំមិនដឹងដែរ ខ្ញុំនៅស្រុកនេះ ហើយគាត់នៅនោះយើងម៉េចហ្នឹងអាចដឹងបាន គាត់នៅកំពង់ចាមនោះហ្នឹង ។

វណ្ណៈ ចុះពូនៅភ្នំដងរែក ហើយដល់ពេលដល់ភ្នំដងរែកហ្នឹងនៅឆ្នាំ៧៩ដដែលទេណោះ?

ឆួរៈ បាទ!

វណ្ណៈ ហើយពេលរត់តាមផ្លូវមានមនុស្សស្លាប់ច្រើនទេ?

ឆួរៈ ស្លាប់ទាំងទ័ពទាំងប្រជាជន ហើយប្រពន្ធខ្ញុំហ្នឹងដើរអត់រួចទេ តែខ្ញុំនឹកឃើញ គ្មានកម្លាំងពីណាតែខ្ញុំអ៊ាវកពីក្រោយ ហើយកូនមួយទៀត ហើយមហាវេទនាហើយ ។

វណ្ណៈ អញ្ចឹងជួបគ្រោះថ្នាក់វេទនាច្រើនតាមផ្លូវ កាល៧៩ហ្នឹងច្រើនណាស់?

ឆួរៈ ស្លាប់គរហូត ។

វណ្ណៈ ចុះពូនៅភ្នំដងរែកហ្នឹងបានរយៈពេលប៉ុន្មានហើយពូចល័តទៅទៀត?

ឆួរៈ ទៅអន្លង់វែង ។

វណ្ណៈ ទៅអន្លង់វែងជាមួយតាម៉ុក?

ឆួរៈ នៅជាមួយតាម៉ុក ។

វណ្ណៈ ក្រុមតាម៉ុកណោះ?

ឆួរៈ បាទ!

វណ្ណៈ ពូនៅអន្លង់វែងរហូតដល់ពេលណា?

ឆួរៈ ប្រហែលជាមួយឆ្នាំ ។

វណ្ណៈ ចុះពូនៅអន្លង់វែងហ្នឹង កាលហ្នឹងជាតំបន់ព្រៃភ្នំ ឬក៏ជាតំបន់អី ហើយមានប្រជាជនរស់នៅទេ?

ឆួរៈ អត់មានទេ សុទ្ធតែព្រៃហ្នឹង ។

វណ្ណៈ ដឹបូងអត់មានប្រជាជនរស់នៅទេណោះ?

ឆួរៈ បាទ!

វណ្ណៈ អាហ្នឹងកាលឆ្នាំ១៩៧៩?

ឆ្នូវៈ បាទ!

វណ្ណៈ មានតែប្រជាជនហើយនឹងទ័ពទេដែលតស៊ូជាមួយវៀតណាម?

ឆ្នូវៈ ហ្នឹងអើយ ។

វណ្ណៈ ហើយកាលហ្នឹងពូមានកូនប្រពន្ធពូនៅវៃជាមួយវៀតណាមដែរឬក៏នៅជាប្រជាជន?

ឆ្នូវៈ គេហៅថានៅខាងក្រោយ ។

វណ្ណៈ នៅសមរភូមិក្រោយ នៅដឹកជញ្ជូនស្បៀង?

ឆ្នូវៈ ជញ្ជូនស្បៀង ។

វណ្ណៈ ហើយជញ្ជូនស្បៀងដូចជាគ្រាប់ ដូចជាស្បៀងអីបានមកពីខាងណាដួយ?

ឆ្នូវៈ បានមកពីចិន ។

វណ្ណៈ ពូមានដឹងថាចិនឈប់ជួយខាងយោធាខ្មែរក្រហមតាំងពីឆ្នាំណាទេ នៅពេលវៀតណាមដកចេញ ឬក៏ម៉េច បើតាមពូគិត?

ឆ្នូវៈ ខ្ញុំដូចជាអត់ចាំដែរហ្នឹង ។

វណ្ណៈ អ្នកខ្លះនិយាយថា ពេលដែលវៀតណាមដកចេញពីប្រទេសកម្ពុជានៅឆ្នាំ៨៧ហ្នឹងគឺចិនឈប់ជំនួយហើយដូចថាខ្មែរយើងវៃជាមួយខ្មែរ អាហ្នឹងគឺខាងកម្លាំងខ្មែរក្រហមដោះស្រាយដោយខ្លួនឯង ។

ឆ្នូវៈ បាទ! អាហ្នឹងដោះស្រាយដោយខ្លួនឯង ។

វណ្ណៈ មានឈើកាប់ឈើ មានត្បូងជីកត្បូងទៅនៅតាមតំបន់ផ្សេងៗ អញ្ចឹងមែនឬក៏មិនមែនទេ?

ឆ្នូវៈ អញ្ចឹងហើយ ។

វណ្ណៈ ហើយពូនៅអន្លុងវែងហ្នឹងដូចថាកាលមុន ពូមានដឹងរឿងរ៉ាវទេកាលដែលសុន សេនគេសម្លាប់នៅអន្លុងអីហ្នឹងពូមានដឹងទេ ព្រោះពូនៅហ្នឹងដែរ?

ឆ្នូវៈ ខ្ញុំអត់នៅហ្នឹងផង ខ្ញុំមកនេះវិញហើយហ្នឹងមកតាមសុន សេន ។

វណ្ណៈ អ៎ សុន សេន យកពូមកនេះវិញហើយគាត់ទៅនៅនោះវិញ?

ឆ្នូវៈ គាត់ដល់ពេលមានបញ្ហាអញ្ចឹងគាត់ទៅនៅជិតតាម៉ុកហើយ ។

វណ្ណៈ គាត់ទៅនៅជិតតាម៉ុក?

ឆ្នូវៈ គេផ្តាច់ខ្លួនហើយគាត់រត់ទៅនោះ ។

វណ្ណៈ ចុះនៅនេះគេផ្តាច់ខ្លួនឆ្នាំណា ផ្តាច់ខ្លួនចូលជាមួយរដ្ឋាភិបាល?

ឆ្នូវៈ អត់ចាំទេអូនអើយ ។

វណ្ណៈ  អត់ចាំទេ?

ឆូវៈ  បាទ! ព្រោះអត់មានបានកត់ត្រាទុកផង ។

វណ្ណៈ  ចុះដូចថានៅនោះតំបន់សុន សេនកាន់កាប់ ចុះពូមានធ្លាប់រស់នៅខាងភូមិដូង ម៉ាឡៃអីទេ?

ឆូវៈ  អត់ដែលទេ ។

វណ្ណៈ  ចុះនៅខាងភូមិដូងម៉ាឡៃពូថាមានគោលការណ៍ដូចថាសុន សេនគាត់ចង់ប្រមូលម៉ូតូ ត្រាក់ទ័រដាក់រួម នៅខាងកំរៀងយើងនេះមានធ្វើអញ្ចឹងដែរអត់ទេ?

ឆូវៈ  ធ្វើដូចគ្នា ។

វណ្ណៈ  មានចង់ប្រមូលទ្រព្យសម្បត្តិដែរ?

ឆូវៈ  ប្រមូល ។

វណ្ណៈ  មានប្រមូលហើយពូក៏មិនទាន់ទេ ដូចថាគ្រាន់តែជាគោលការណ៍?

ឆូវៈ  ប្រមូលហើយ មានម៉ាស៊ីនអារឈើ ម៉ាស៊ីនអីហ្នឹងយកមកដាក់រួមមក ។

វណ្ណៈ  អញ្ចឹងមានប្រមូលដាក់រួមខ្លះហើយណោះ?

ឆូវៈ  បាទ! តែអត់បានទាំងអស់ទេ ។

វណ្ណៈ  ពីណាគេជាអ្នកឲ្យប្រមូល ជាអ្នកបញ្ជា?

ឆូវៈ  សុន សេនហ្នឹងគាត់ជាអ្នកគ្រប់គ្រងនៅនេះ តែមិនដឹងថាមានបញ្ជាពីណាមកទេខ្ញុំមិនដឹងទេ ។

វណ្ណៈ  អញ្ចឹងសុន សេនគាត់គ្រប់គ្រងតែនៅកំរៀងនេះទេ ហើយនៅម៉ាឡៃតាអៀង សារីប៊ុក៏គាត់ដែរ?

ឆូវៈ  តាអៀង សារីគាត់នៅខាង.... ។

វណ្ណៈ  អគ្គបញ្ជាការក្រសួងការបរទេស?

ឆូវៈ  គាត់នៅគ្រប់គ្រងខាងប៉ៃលិន ។

វណ្ណៈ  នៅប៉ៃលិន ហើយនឹងម៉ាឡៃ?

ឆូវៈ  បាទ!

វណ្ណៈ  អញ្ចឹងនៅនោះតាសុន សេន?

ឆូវៈ  ហ្នឹងអើយ ។

វណ្ណៈ  ចុះតាខៀវ សំផននៅនេះដែរ?

ឆូវៈ  ខៀវ សំផនអត់មាននៅនេះទេ តែមិនដឹងថាគាត់នៅណាទេ ។

វណ្ណៈ  ចុះតាប៉ុល ពត?

ផ្លូវៈ ប៉ុល ពតនៅអន្លង់វែង ។

វណ្ណៈ ចុះដូចជាកាលឆ្នាំ៨០ ជាងសម្តេចសីហនុមានបានយាងមកដល់នេះដែរឬអត់ទេ?

ផ្លូវៈ អត់ទេ ។

វណ្ណៈ អញ្ចឹងមកដល់ត្រឹមម៉ាឡៃទេ?

ផ្លូវៈ បាទ!

វណ្ណៈ ចុះពូស្រុកកំរៀងនេះទើបតែកើតថ្មីដូចម៉ាឡៃដែរ?

ផ្លូវៈ ទើបតែកើតថ្មី ។

វណ្ណៈ និយាយពីសង្គមបុរាណចាស់ដូចថាកាលពី១០០ឆ្នាំមុននៅនេះមានភូមិអញ្ចឹងដែរ?

ផ្លូវៈ មានភូមិកំរៀង ។

វណ្ណៈ នៅភូមិកំរៀងគេថាមានភូមិចាស់បន្តិច គេថាជនជាតិទៀត?

ផ្លូវៈ មិនដឹងម៉េចទេ ខ្ញុំមិនដឹងដែរ ។

វណ្ណៈ បើនៅនេះសុទ្ធតែព្រៃ?

ផ្លូវៈ បាទ!

វណ្ណៈ ព្រៃច្រើនមែនទែនឬក៏ម៉េចពូ?

ផ្លូវៈ សុទ្ធតែដើមឈើ ។

វណ្ណៈ ដើមបេងដើមអីមានទេពូ?

ផ្លូវៈ ដើមបេងដើមអីហ្នឹងច្រើនណាស់ និយាយរួមទៅសុទ្ធតែដើមឈើហ្នឹង គ្មានផ្លូវគ្មានអីទេ ។

វណ្ណៈ ដើមឈើធំៗណាស់?

ផ្លូវៈ ព្រៃឬស្សីហ្នឹងច្រើនណាស់ ។

វណ្ណៈ ហើយចុះកើតជាភូមិជាអីអញ្ចឹងប្រហែលជានៅឆ្នាំណាទៅបានកើតជាភូមិជាវាលអញ្ចឹង?

ផ្លូវៈ អាហ្នឹងមកនៅនេះបានមួយឆ្នាំហើយ តាសុន សេនគាត់ឲ្យ កាលមុននៅនោះ នៅតាមមាត់អូរនោះ ។

វណ្ណៈ អត់មានអ្នកណានៅនេះទេ?

ផ្លូវៈ អត់មានទេ ព្រោះនៅនេះអត់មានទឹក ។

វណ្ណៈ ហើយនៅនោះជីកអូរអញ្ចឹងចាញ់ទេ?

ផ្លូវៈ ចាញ់ ជីកហើយចាញ់គ្រប់គ្នាហ្នឹង ។

វណ្ណៈ យើងយកមកដាំទៅ ។

ឆ្លូវៈ ដាំ ។

វណ្ណៈ ដាំហើយបានដឹក?

ឆ្លូវៈ ដូនកាលយើងដឹកអណ្តូងក្នុងអូរដែរហ្នឹង ដល់ក្រោយមកបានឡើងមកនៅនេះ នៅនេះហើយបានតាសុន សេនគាត់ដឹកស្រះមួយធំហ្នឹង ។

វណ្ណៈ ហើយមានទឹកដល់រាល់ថ្ងៃហ្នឹង?

ឆ្លូវៈ បាទ! មានដល់សព្វថ្ងៃនេះ ។

វណ្ណៈ ស្រះធំ?

ឆ្លូវៈ បាទ!

វណ្ណៈ ហ្នឹងសុន សេនគាត់ដឹកណោះ?

ឆ្លូវៈ បាទ!

វណ្ណៈ ចុះប្រជាជនមកនៅនេះប្រហែលជាឆ្នាំប៉ុន្មានពូ?

ឆ្លូវៈ ខ្ញុំភ្លេចហើយ ។

វណ្ណៈ តាំងពីឆ្នាំ៩០ឬក៏មិនមែនទេ?

ឆ្លូវៈ ប្រហែលជាប៉ុណ្ណឹងហើយ ។

វណ្ណៈ ហើយអត់មានផ្ទះទេ មានតែប្រជាជននាំគ្នាធ្វើខ្ទម?

ឆ្លូវៈ សុទ្ធតែព្រៃទាំងអស់ ។

វណ្ណៈ នាំគ្នាធ្វើខ្ទមនៅតាមមាត់អូរណោះ?

ឆ្លូវៈ នៅតាមមាត់អូរ ។

វណ្ណៈ ដល់ក្រោយមកបានមកនៅតាមនេះ?

ឆ្លូវៈ បាទ!

វណ្ណៈ ចុះពូនៅនេះកាលហ្នឹងពូមកនៅហ្នឹងនៅវៃជាមួយយួននៅឡើយទេ?

ឆ្លូវៈ បាទ! នៅវៃ ។

វណ្ណៈ អញ្ចឹងមុនឆ្នាំ៩០ទៀត បើវៃមានតែវៃជាមួយទាហានខាងក្នុងទេអត់មានយួនទេ?

ឆ្លូវៈ ហ្នឹងអើយ ។

វណ្ណៈ វៃជាមួយទាហានខាងក្នុងស្លាប់មនុស្សយ៉ាងម៉េចដែរ ដូចគ្នាដែរឬក៏ម៉េច?

ឆ្លូវៈ ស្លាប់ដូចតែគ្នាហ្នឹង ។

វណ្ណៈ ចុះមីននៅខាងហ្នឹងមានខាងណាដាក់ខ្លះ?

ឆ្នូវៈ កាលហ្នឹងមានយួនដាក់ខ្លះ ហើយដល់ពេលយួនដកចេញមាននៅសល់ខាងក“៥ ។”

វណ្ណៈ ដាក់ទាំងសងខាង?

ឆ្នូវៈ ដាក់ទាំងសងខាង ។

វណ្ណៈ ស្លាប់ដូចគ្នា?

ឆ្នូវៈ បាទ!

វណ្ណៈ តែពូស្រមៃមើលថាសង្គ្រាមធ្វើឲ្យខាតជីវិតមនុស្សយ៉ាងម៉េចដែរពូ?

ឆ្នូវៈ បើគិតទៅវាសម្លាប់តែខ្មែរគ្នាឯង សំខាន់រងគ្រោះជាងគេគឺខ្មែរឯងហ្នឹង ខ្មែរវ៉ៃខ្មែរ ហើយខ្មែរខាងក្រៅនេះក៏វ៉ៃខ្មែរឯងទៀត ។

វណ្ណៈ ខ្ញុំសូមសង្ខេបបន្តិចទៅហ្នឹងកាលគ្រប់គ្រង៣ឆ្នាំហ្នឹង ពូគិតថាជាកំហុសរបស់ថ្នាក់លើឬជាកំហុសរបស់ថ្នាក់ក្រោម?

ឆ្នូវៈ អាហ្នឹងជាកំហុសរបស់ថ្នាក់លើបន្តិចហើយ ។

វណ្ណៈ អញ្ចឹង?

ឆ្នូវៈ បើគ្មានបញ្ជាពីខាងលើមកក៏គ្មានអ្នកណាហ៊ានធ្វើដែរ គេគោរពតាមបញ្ជាថ្នាក់លើ ដូចពាក្យស្លោកគេថាថ្នាក់ក្រោមគោរពថ្នាក់លើ ។

វណ្ណៈ ចុះពូខ្ញុំគិតថាពូធ្លាប់ឆ្លងកាត់របបជាច្រើនជំនាន់ ពូគិតថាបើយើងគិតមើលថាយើងនិយាយនូវអ្វីដែលយើងបានដឹង ហើយនូវអ្វីដែលយើងបានឃើញជាក់ស្តែង ពូគិតថាពីមុនពីសម័យតស៊ូមកដល់ឥលូវនេះ តើការរស់នៅរបស់ប្រជាជនមួយណាបានស្រួលជាង កាលមុនស្រួលជាងឬក៏ឥលូវនេះស្រួលជាង?

ឆ្នូវៈ ពីមុនអត់បានសុខសាន្តទេ ហើយឥលូវយើងបានសុខសាន្ត ហើយរកស៊ីក៏បានដូចថារីកចម្រើនដែរ ។

វណ្ណៈ អ្នកណារកអ្នកហ្នឹងបានទៅ អត់មានពីណាមកយករបស់យើងទៀតទេ?

ឆ្នូវៈ អ្នកណាខំអ្នកហ្នឹងបាន ។

វណ្ណៈ អញ្ចឹងពូគិតថាឥលូវនេះស្រួលជាងពីមុន?

ឆ្នូវៈ បាទ!

វណ្ណៈ អញ្ចឹងខ្ញុំចង់សួរពូដែរកាលជំនាន់៣ឆ្នាំហ្នឹង ពូមានធ្លាប់ជួយពីណាទេ ដូចថាគេខុសឆ្គងហើយពូមានធ្លាប់ជួយគេដែរទេ ហ៊ានជួយគេដែរទេកាលហ្នឹង?

ឆ្នូវៈ ដូចថាគេខុសសិលធម៌ម្តងមួយយាមអីខ្ញុំអត់អោនច្រើនណាស់ ។

វណ្ណៈ ជួយលើកលែនដែរ?

ធួវៈ បាទ!

វណ្ណៈ ដល់ពេលញឹកច្រើនដងយើងជួយមិនបានដែរណោះ?

ធួវៈ បាទ!

វណ្ណៈ ចុះអ្នកដែលជួយពូអាចស្គាល់ឈ្មោះគេដែរទេ?

ធួវៈ អត់ស្គាល់ទេ ។

វណ្ណៈ ពូអត់ស្គាល់ទេ?

ធួវៈ អញ្ចឹងបានថាឲ្យតែពេលខ្ញុំទៅគេនាំគ្នាថា អ៎លោកតាមកទៀតហើយ ហើយតែខ្ញុំទៅហើយគឺអត់ដែលអត់ទេ បើចាស់ៗច្រើនតែថ្នាំ ហើយនឹងម្ហូបស្អីហ្នឹងខ្ញុំតែងតែដាក់យកទៅហើយ ។

វណ្ណៈ ចុះពូតាំងពីពូមកនៅនេះបែកស្រុកកំណើតប្រហែលជាប៉ុន្មានឆ្នាំហើយ?

ធួវៈ បែកជាង៣០ឆ្នាំហើយ ។

វណ្ណៈ អញ្ចឹងតាំងពីពូមករស់នៅនេះ ពូបានទៅលេងស្រុកកំណើតប្រហែលជាប៉ុន្មានដងហើយ?

ធួវៈ បានទៅ៣ដងហើយ ។

វណ្ណៈ ពេលសាមារណកម្មហើយ?

ធួវៈ បាទ!

វណ្ណៈ ចុះមកដល់សព្វថ្ងៃពូមានគំនិតចង់ទៅរស់នៅស្រុកកំណើតវិញដែរឬទេ ដូចថាមានទិសដៅថាត្រូវតែបោះទីតាំងនៅនេះហើយ កូនចៅនៅនេះអញ្ចឹង?

ធួវៈ អត់គិតថាទៅស្រុកកំណើតវិញទេ ។

វណ្ណៈ ហេតុអី?

ធួវៈ បាទ!

វណ្ណៈ ហេតុអីបានជាពូចង់នៅនេះ?

ធួវៈ នឹកឃើញថាទៅនៅស្រុកវាដីចង្អៀត ហើយនៅនេះដីទូលាយ ហើយការរកស៊ីអីក៏វាគ្រាន់បើជាង នៅនោះមានធ្វើអី ធ្វើតែស្រែហើយក្រឡេមក្រឡឹមដឹកតែទឹកត្នោតដូហ្នឹង ។

វណ្ណៈ អញ្ចឹងនៅនេះស្រួលជាងណោះ?

ធួវៈ ព្រោះនៅនោះអត់មានស្រូវមិនដឹងធ្វើអីទេ ។

វណ្ណៈ ហើយនៅនេះអត់មានទំនេរទេពូណោះ?

ធួវៈ អត់មានទំនេរទេ ។

វណ្ណៈ ធ្វើអញ្ចឹងរហូតទៅ ហើយបើមានអ្នកទំនេរនៅក្នុងភូមិនេះទៅស៊ីឈ្នួលនៅថៃដែរឬក៏អត់ទេ?

ផ្លូវៈ មិនមានទេ មានតែអ្នកមកពីខាងក្រៅ ។

វណ្ណៈ ហើយបើខាងក្នុងភាគច្រើនទៅស៊ីឈ្នួលនៅថៃណោះ បើនៅនេះគេមានដីធ្វើហើយមិនជួបបញ្ហាអីទេ ។

ផ្លូវៈ មិនទៅទេ ហើយម្យ៉ាងទៀតទៅក៏គ្មានចំនេញអីទេ តែអាហ្នឹងការរស់នៅវាខុសៗគ្នាទាំ បើយើងទៅហ្នឹងជួនកាលខុសច្បាប់គេទាត់គេធាក់ គេរុញគេច្រាន គេចង់ឲ្យប្រាក់ខែក៏បានមិនឲ្យក៏បាន មិនល្អអីជាងនៅស្រុកយើងទេកូន ទៅធ្វើការងារនៅស្រុកថៃក៏គ្រាន់បើជាងដែរ ។

វណ្ណៈ ចុះពូមកដល់ឥលូវខ្ញុំចង់សួរសន្មេបបន្តិចទៀតថា ដូចជាពូសព្វថ្ងៃហ្នឹងកាលជំនាន់៣ឆ្នាំហ្នឹងមានជីវិតមនុស្សស្លាប់ប្រហែលជាង១លាននាក់ ហើយមានតួលេខខ្លះថាមានទៅដល់៣លាននាក់ទាំងកាល៧/៤ដោយសារថាយើងបូកមិនបានច្បាស់លាស់ គ្រាន់តែសួរសាច់ញាតិបងប្អូនដែលបាត់ហ្នឹង តែក្រោយមកអ្នកស្រាវជ្រាវជាន់ខ្ពស់ពីសហរដ្ឋ ហើយអ្នកស្រាវជ្រាវផ្សេងៗទៀតមួយចំនួនទៀតថាប្រជាជនស្លាប់តែជាងមួយលាននាក់ក្នុងសម័យហ្នឹង ហើយដោយសារថាប្រជាជនស្លាប់ច្រើនអញ្ចឹងហើយ ហើយប្រទេសយើងបានចូលក្នុងអង្គការសហប្រជាជាតិពីយូមកហើយដែរតាំងពីឆ្នាំ៩០ជាងអញ្ចឹង ដល់ពេលអញ្ចឹងគេតម្រូវឲ្យមានការកាត់ទោសមេដឹកនាំណាដែលបានរំលោភសិទ្ធមនុស្ស ហើយនឹងមានការធ្វើឲ្យមនុស្សស្លាប់ច្រើនក្នុងរបបខ្លួនកាន់កាប់ អញ្ចឹងពូគិតថាការដែលឲ្យមានតុលាការហ្នឹងវាជាការត្រឹមត្រូវដែរឬក៏មិនត្រឹមត្រូវទេ អាហ្នឹងតាមទស្សនៈរបស់ពូផ្ទាល់ ។

ផ្លូវៈ អាហ្នឹងវាយោបល់ល្អដែរ ដើម្បីយើងអប់រំអ្នកដឹកនាំក្រោយៗកុំឲ្យមានការប្រព្រឹត្តអញ្ចឹងទៀតព្រោះយើងឃើញថាកាស្លាប់របស់ប្រជាជន ដូចថាវាអត់មានតម្លៃអីដល់ជីវិតម៉ុស្សដែលស្លាប់សោះ និយាយរួមទៅថាមនុស្សហ្នឹង ដូចថាអត់មានច្បាប់មានទម្លាប់ ។

វណ្ណៈ នៅក្នុងសម័យនោះបើតាមចាស់ដែលធ្លាប់ជួបប្រទះគាត់ថា ដេកយប់ដឹងតែពីភ័យ ព្រលឹងឡើមបានដឹងថារស់ទៀត តើពូគិតដូចអញ្ចឹងដែរទេ?

ផ្លូវៈ អាហ្នឹងគាត់គិតអញ្ចឹងក៏វាត្រឹមត្រូវដែរ ព្រោះទាំងគេទាំងខ្ញុំក៏វាអញ្ចឹងដែរ ។

វណ្ណៈ បាទ!

ផ្លូវៈ ខ្ញុំបើនៅតែមួយខែទៀតមិនដឹងយ៉ាងម៉េចផង សួរគេអ្នកដឹកនាំថ្នាក់ក្រោមបំផុតហើយណា៎ ពេលទៅប្រជុំសួរទៅថា ម៉េចហើយឯង ដល់ហើយខ្ញុំឆ្លើយថាបាត់អស់ពីបីនាក់ទៀតហើយ ដល់

ហើយគេថាអញ្ចឹងនៅតែគ្នាបីបួននាក់ទៀតទេ យើងមិនដឹងថ្ងៃណាដែរទេយើង បើយើងស្លាប់ក៏ស្លាប់ទៅចុះឲ្យតែយើងស្មោះនឹងប្រជាជន បើវាត់ក៏មិនដឹងថាវាត់ទៅណាដែរ ។

វណ្ណៈ: កាលសម័យហ្នឹងគឺពិបាកណាស់ពូ ។

ឆូវ: បាទ!

វណ្ណៈ: អញ្ចឹងមកដល់ឥឡូវយើងបានឆ្លងកាត់ពីសង្គ្រាមហើយ ហើយខ្មែរឈប់វ៉ៃខ្មែរទៀតហើយ សព្វថ្ងៃយើងមានបញ្ហាខ្លះៗជាមួយប្រទេសជិតខាង ហើយប្រទេសកម្ពុជាយើងត្រូវរ៉ូវជាមួយប្រទេសជិតខាងទៅ យើងបានផលដំណាំអីយើងលក់ស្រួល ហើយប្រហែលជាប្រទេសជាតិយើងអាចមានការរីកចម្រើនទៅមុខខ្លះមួយចំនួនទៀត ។

ឆូវ: រីកច្រើន ។

វណ្ណៈ: រីកច្រើន?

ឆូវ: ព្រោះថាជាកន្លែងជាប់ព្រំដែនអញ្ចឹង បើគេបិទច្រកជិតយើងមានតែបកក្រោយវិញ ហើយបើក្រោយវិញវាមិនមែនងាយណាំ ។

វណ្ណៈ: វាផ្លូវឆ្ងាយ ។

ឆូវ: ដល់ពេលឆ្ងាយយើងវាធ្លាក់តម្លៃទៀត ។

វណ្ណៈ: បាទ!

ឆូវ: ព្រោះគេគិតទាំងថ្លៃដឹកជញ្ជូន ទាំងថ្លៃកម្មករទៀត មានសល់ប៉ុន្មានបើសាំងប្រេងវាឡើងថ្លៃគេគិតល្អិតណាស់ ។

វណ្ណៈ: ចុះនៅស្រុកកំរៀងយើងតើប្រជាជនគេដាំដំណាំអីជាប្រចាំ ដំណាំអីដែលគេប្រកបមុខរបររាល់ថ្ងៃ?

ឆូវ: មុខរបររបស់ប្រជាជននៅកន្លែងនេះមានតែដំឡូង ពោត សណ្ដែក ល្ង ហើយស្រូវរួមផ្សំ ។

វណ្ណៈ: អញ្ចឹងខ្ញុំដូចជាអស់អីសួរពូទៀតហើយ ហើយពូមានអីចង់បន្ថែមទេ ។

ឆូវ: អញ្ចឹងបានថាសព្វថ្ងៃនេះវាបានស្រួលហើយ ហើយមកដល់សព្វថ្ងៃនេះការដឹកនាំរបស់រាជរដ្ឋាភិបាលឃើញថាមានការរីកចម្រើន ហើយប្រជាជនមានការហូបចុកគ្រប់គ្រាន់ ហើយកន្លែងខ្លះអ្នកខំក៏ធូរធារទៅ ហើយអ្នកមិនខំក៏ខ្សោយបន្តិចទៅ ។

វណ្ណៈ: អញ្ចឹងខ្ញុំអរគុណពូច្រើនហើយ ។

ឆូវ: បាទ!